# ឯកសារព័ត៌មានអំពីចៃក្បាល

## គោលនយោបាយនៃសង្កាត់សាលារៀនអូកឡិនដ៏ : *កូនសិស្សដែលមានចៃក្បាល អាចមកចូលរៀនបាន ប៉ុន្តែការថែទាំ និងការព្យាបាល ត្រូវតែចាប់ផ្តើមធ្វើភ្លាមៗក្រោយពីការបានរកឃើញថាមានចៃក្បាល។*

## តើចៃក្បាលជាអ្វី?

- ចៃក្បាលជាសត្វល្អិតចង្រៃ ដែលអាចរកឃើញនៅលើក្បាល ចិញ្ចើម និងរោមភ្នែកនៃមនុស្ស។
- ចៃក្បាលបឺតឈាមមនុស្សជាអាហារ ជាច្រើនដងក្នុងមួយថ្ងៃ ហើយរស់នៅជាប់លើស្បែកក្បាលមនុស្ស។
- ចៃក្បាលមិនចម្លងមេរោគទេ។
- ផលវិបាកខ្លាំងជាងគេចំពោះចៃក្បាល គឺដំបៅក្លាយកើតចេញពីការអេះ។
- ចៃក្បាល មិនអាចរស់បានយូរលើសពីរបីម៉ោង នៅពេលដែលវានៅឆ្ងាយពីខ្លួនប្រាណមនុស្ស ដោយសារតែវានឹងខ្សោះទឹកពីខ្លួន។
- ចៃក្បាល មិនចាកចេញពីស្បែកក្បាលទេ លុះត្រាតែវាងាប់ ជិតងាប់ ឬត្រូវបានបូតចេញពីសក់ក្បាល។
- ចៃក្បាល មិនចេះហោះហើរ លោត ឬហែលទឹកឡើយ។

## តើពងចៃក្បាលជាអ្វី?

- ពងចៃក្បាល គឺជាពងដែលចៃឈ្មោលបានដាក់បញ្ចូលមេជីវិតចៃ។
- ពងចៃត្រូវតែនៅជាប់លើសសៃសក់ក្នុងចម្ងាយ 1/4 អ៊ីង ពីស្បែកក្បាល ដើម្បីភ្ញាស់កូនចៃ។
- បើសិនជាពងចៃត្រូវបានរកឃើញនៅជាប់សសៃសក់ក្នុងចម្ងាយ 1 សង់ទីម៉ែត្រ ពីស្បែកក្បាលនោះ គឺមានន័យថាវាបានញាស់ជាកូនចៃ ឬបានងាប់បាត់ហើយ។
- ពងចៃ គឺពុំត្រូវចាំបាច់ព្យាបាលដោយថ្នាំគីមីទេ; រើសរកចៃដែលនៅមានជីវិតក្នុងរយៈពេល 7-10 ថ្ងៃ។

## តើចៃក្បាលឆ្លងរបៀបណា?

- ចៃក្បាល ឆ្លងយ៉ាងលឿនបំផុត តាមការប៉ះក្បាលទល់នឹងក្បាលដោយផ្ទាល់។
- ការប្រើប្រាស់រួមគ្នា នូវមួកធម្មតា មួកដែក ស្និតសិតសក់ គ្រឿងលំអក្បាល ហើយផលិតផលផ្សេងៗទៀតសំរាប់សក់ ក៏អាចឆ្លងចៃក្បាលផងដែរ។
- ចៃក្បាលមិនចេះលោតចេញពីក្បាលមនុស្សទៅកាន់មនុស្សម្នាក់ទៀតទេ។
- ចៃក្បាលមនុស្ស គឺរស់នៅតែលើក្បាលមនុស្ស ហើយថាវាមិនរស់នៅលើសត្វឡើយ។
- ការមានចៃក្បាល គឺពុំមែនជាសញ្ញាថាគ្មានអនាម័យ សក់មិនស្អាត ឬខ្វះការថែទាំពីមាតាបិតានោះទេ។ អ្នកណាដែលមានសក់វែង ឬខ្លី សក់ស្អាត ឬមិនស្អាត ក៏អាចមានចៃក្បាលដូចគ្នាដែរ។
- ចៃក្បាល គឺមិនបង្កើរឡើងដោយធូលី ហើយមិនរស់នៅក្នុងបរិស្ថានទេ។

## ត្រូវធ្វើអ្វីខ្លះ :

- វាជាការល្អ ក្នុងការបោកកម្រាលពូក កន្សែងពោះគោ កូនតុក្កតាសត្វញាត់សំឡី ដែលកុមារគេងអោប រួចដាក់ហាលដោយកម្តៅអោយស្ងួត ដើម្បីកម្ចាត់ចៃ ឬពងចៃ។
- វាជាការល្អ ក្នុងលាងជម្រះស្និតសិតសក់ ច្រាស់ មួក និងគ្រឿងប្រដាប់ប្រដារផ្សេងៗទៀតសំរាប់សក់ ដោយទឹកក្តៅ នៅថ្ងៃនីមួយៗ ដើម្បីកំចាត់ចៃ និងពងចៃណាមួយអោយអស់។
- កុមារត្រូវចៀសវាងក្នុងការប៉ះទង្គិចក្បាលគ្នា នៅពេលណាពួកគេបំពេញកិច្ចការតាមក្រុម នៅពេលលេងល្បែងកំសាន្ត ។ល។
- ចៃក្បាលអាចព្យាបាលបាន ដោយប្រើថ្នាំគីមី ឬដោយស្និតញឹកសិតយកចៃចេញពីក្បាល។ ពាក្យណែនាំពីរបៀបព្យាបាលចៃក្បាល គឺមានដាក់ជូននៅក្នុងទំព័របន្ទាប់មកទៀត។

# របៀបព្យាបាលចៃក្បាល

**សារៈសំខាន់ :** ព្យាបាលត្រូវចំពោះមនុស្សណាដែលមានចៃនៅរស់។
សូមរែកសក់រកមើលវា ដើម្បីអោយឃើញថា គេមាន ឬពុំមានចៃដែលនៅមានជីវិតរស់នៅលើក្បាល។

## ព្យាបាលដោយថ្នាំគីមី

ទីភ្នាក់ងារ FDA បានយល់ព្រមថា ថ្នាំសម្លាប់ចៃ Cream Rinse ដែលមានជាតិ Permethrin (1%) គឺជាថ្នាំព្យាបាលដ៏មានប្រសិទ្ធភាពបំផុត សំរាប់កក់សក់កំចាត់ចៃចេញពីក្បាល។ សូមស្នើសុំអោយឱសថការី នៅតាមហាងលក់ថ្នាំពេទ្យរបស់លោកអ្នក ជួយរកថ្នាំកក់សក់ ដែលមានជាតិ Permethrin។ សូមធ្វើតាមពាក្យណែនាំនានានៅលើស្លាក។

1. មុនប្រើថ្នាំកក់សក់ សូមដោះចេញនូវសម្លៀកបំពាក់ចាប់ត្រឹមពីចង្កេះឡើងលើ។ សូមកុំកក់សក់នៅក្នុងទឹ ឬអាងងូតទឹកផ្កាឈូក។ សុំអោយកុមារផ្អៀងក្បាលទៅលើស្អកទឹក រួចលាបថ្នាំកក់សក់។
2. លាបផលិតផលសម្លាប់ចៃ លើសក់ស្ងួត តាមពាក្យណែនាំនានានៅលើស្លាក។
3. សូមកុំទាន់លាងសក់ចេញ សំរាប់រយៈពេល 1-2 ថ្ងៃ ក្រោយពីការដាក់ថ្នាំសម្លាប់ចៃ។ ប្រើតែសាប៊ូកក់សក់ shampoo ធម្មតា សំរាប់រយៈពេលពីរសប្តាហ៍ ក្រោយពីការបានដាក់ថ្នាំសម្លាប់ចៃ សូមកុំប្រើថ្នាំសម្លាប់ចៃ ឬសាប៊ូ shampoo ដែលមាន conditioning។
4. ក្រោយពីការដាក់ថ្នាំសម្លាប់ចៃមក សូមប្រើស្និតញឹកធ្វើពីដែកសំរាប់សិតសក់យកមេចៃ និងពងចៃចេញពីសសៃសក់។ ការសិតសក់យកពងចៃណាដែលនៅរស់ ក្រោយពីការដាក់ថ្នាំសម្លាប់ចៃ ត្រូវបានស្នើសុំអោយធ្វើ ប៉ុន្តែមិនតម្រូវតែ។
5. បើសិននៅឃើញមានចៃនៅរស់លើក្បាល លោកអ្នកលាបថ្នាំសម្លាប់ចៃម្តងទៀតបាន ក្នុងរយៈពេលពី 7-10 ថ្ងៃ; សូមកុំលាបថ្នាំម្តងទៀត បើសិនជាកូនលោកអ្នកគ្រាន់តែរមាស់ ឬនិយាយប្រាប់ថា រមាស់ក្បាល។
6. បន្តឆែកមើលមនុស្សដែលបានលាបថ្នាំសម្លាប់ចៃ សំរាប់រយៈពេល 2-3 សប្តាហ៍ ក្រោយពីលោកអ្នកគិតថា ពួកគេលែងមានចៃទៀតហើយ។
7. បើសិនជាក្បាលគេកើតមានចៃឡើងវិញ សូមជួបវេជ្ជបណ្ឌិតរបស់កូនលោកអ្នក ក្រែងលោត្រូវការថ្នាំកក់សក់ចេញពីពេទ្យ។

## ជម្រើសកំចាត់ចៃតាមការប្រើស្និតញឹកសិតសក់

បើសិនជាលោកអ្នកសំរេចចិត្តយកពេលសាកល្បងកំចាត់មេចៃ និងពងចៃ ដោយប្រើស្និតញឹកសិតសក់ ជាជាងប្រើថ្នាំសម្លាប់ចៃ :

1. សិតសក់កូនរបស់លោកអ្នកជារៀងរាល់ថ្ងៃ សំរាប់រយៈពេលពីរសប្តាហ៍ ដើម្បីសិតយកចៃដែលនៅរស់
2. ប្រើភ្លើងដែលមានពន្លឺភ្លឺ កែវពង្រីក និងស្និតញឹកល្អសំរាប់សិតយកមេចៃ និងពងចៃ ព្រមទាំងសត្វល្អិតចេញពីក្បាល។ យើងខ្ញុំស្នើសុំ កុំអោយប្រើស្និតអេឡិចត្រូនិច ឬស្និតសិតឆក់ចៃ ដោយសារតែវាពុំអាចសិតដល់ស្បែកក្បាល ដើម្បីឆក់មេចៃ ឬពងចៃ។
3. អង្គុយពីក្រោយកូន ប្រើភ្លើងដែលមានពន្លឺភ្លឺ ដើម្បីបញ្ជាំង និងសិតសក់រែករកមេចៃ និងពងចៃ ម្តងបន្តិចៗ។ សិតហើយសិតទៀត រហូតទាល់តែលែងឃើញមានចៃ។
4. ស្និតញឹកល្អៗ គឺមានលក់ក្នុងតម្លៃថោកៗ នៅតាមហាងលក់ឱសថ។ ស្និតញឹកដែលធ្វើពីដែក គឺល្អជាងស្និតញឹកធ្វើពីផ្លាស្ទិក។
5. សក់ត្រង់ គឺងាយសិត ខណៈដែលសក់រួញក្រាស់ អាចមានការពិបាក ក្នុងការសិតយកចៃចេញពីសក់ក្បាល ហើយអាចធ្វើអោយឈឺផង។ នេះគឺជាអ្វីដែលត្រូវគិត ក្នុងការសំរេចចិត្តរបស់លោកអ្នក ដើម្បីសាកល្បងបូតយកមេចៃ និងពងចៃចេញពីសក់ក្បាល។
6. ទោះបីជាសក់ក្បាលហាក់បីដូចជាពោរពេញទៅដោយពងចៃក៏ដោយ ក៏មេចៃសកម្មមិនមានលើសពីចំនួនដប់ពីរមេឡើយ។
7. ពងចៃដែលនៅជាប់សសៃសក់ក្នុងចម្ងាយ 1/2 អ៊ីង ពីស្បែកក្បាល តាមធម្មតា គឺបានញាស់រួចហើយ ហើយថាគ្មានកូនចៃក្នុងហ្នឹងទៀតទេ។
8. សក់ត្រូវមានភាពស្អាតបាត ហើយសិតអោយបានស្អាត ឬសិតអោយត្រង់ មុននឹងប្រើស្និតញឹកសិតយកចៃចេញ។
9. សម្អាតស្និតអោយបានញឹកញាប់ ដើម្បីកុំអោយមានជាប់មេចៃ ឬពងចៃ។
10. លោកអ្នកអាចត្រូវការពេលវេលាជាច្រើនម៉ោងក្នុងយប់និមួយៗ អស់រយៈពេលជាច្រើនយប់ ដើម្បីកំចាត់ចៃអោយអស់ពីក្បាល។

# គោលនយោបាយនៃសង្កាត់សាលារៀនអូកឡិនដ៏ចំពោះចៃលើក្បាល

សង្កាត់ កំណត់ន័យលើ បរិស្ថានចំរើនសុខភាព និងសុវត្ថិភាព ថាជាទីកន្លែងមួយ ដែលមនុស្សពេញវ័យធ្វើការរួមគ្នា ដើម្បីផ្តល់កត្តាបរិស្ថាន ដូចតទៅនេះ ដែលបានបង្កើតឡើង តាមសម្រាវជ្រាវចាំបាច់ ដើម្បីសុខភាព និងសុខមាលភាពនៃកូនសិស្ស ដែលមានចៃលើក្បាល :

- ផ្តល់ចំណេះដឹងដល់បុគ្គលិក កូនសិស្ស និងមាតាបិតា ឬអ្នកអាណាព្យាបាល អំពីចៃលើក្បាល។
- បង្កើតរបៀបគ្រប់គ្រងផ្នែកលើភស្តុតាង សំរាប់កូនសិស្សដែលមានចៃលើក្បាល។

គោលដៅនៃការផ្តល់អោយបរិស្ថានចំរើនសុខភាព និងសុវត្ថិភាព សំរាប់កូនសិស្ស ដែលមានចៃក្បាល គឺដើម្បី :

- ធ្វើអោយការសិក្សាមុខវិជ្ជាសិក្សាមានលក្ខណៈកាន់តែខ្លាំងឡើងដល់កំរិតអតិបរិមា
- ធ្វើអោយការខានមករៀនមានចំនួនតិចបំផុត ដោយសារតែការមិនអនុញ្ញាតអោយមកចូលរៀនដោយគ្មានការចាំចាច់ចំពោះកូនសិស្ស ដែលមានចៃក្បាល។

ដើម្បីគ្រប់គ្រងអោយបានជិតដល់ និងដើម្បីរិតរឹតត្បិតការឆ្លងចៃក្បាលនោះ បុគ្គលិកសាលារៀន ត្រូវរាយការណ៍ប្រាប់ពីករណីទាំងអស់ ដែលត្រូវបានសង្ស័យថាមានចៃក្បាលដល់គិលានុបដ្ឋាយិកាប្រចាំសាលារៀន ឬអ្នកចាត់តាំង ដែលនឹងធ្វើការពិនិត្យលើកូនសិស្ស។

**បើសិនជាគិលានុបដ្ឋាយិកាប្រចាំសាលារៀនមិននៅ សូមទូរស័ព្ទទៅកាន់ផ្នែកបំរើសេវាសុខភាព តាមរយៈលេខ (510) 273-1510។ កំណត់សំគាល់ : ការរកមេចៃ និងពងចៃ គឺពុំមែនជាកិច្ចការបន្ទាន់ទេ។ គិលានុបដ្ឋាយិកាម្នាក់ នឹងត្រូវបានបញ្ជូនអោយទៅកាន់ទីសាលារៀន នៅពេលណាចអាចរកបាន។**

## ពងចៃ

បើសិនជាជាពងចៃត្រូវបានរកឃើញ ប៉ុន្តែអត់មានឃើញមេចៃនៅរស់នោះ គិលានុបដ្ឋាយិកាប្រចាំសាលារៀន ឬអ្នកចាត់តាំង នឹងត្រូវបានបញ្ជូនអោយទៅធ្វើការពិនិត្យសារជាថ្មីក្នុងរយៈពេលពី 7-10 ថ្ងៃ; ការព្យាបាលគឺពុំត្រូវការចាំទេក្នុងពេលនេះ។

## មេចៃនៅរស់ (ឃើញវារវើកៗ)

បើសិនជាមេចៃនៅរស់ (វារវើកៗ) ត្រូវបានរកឃើញនៅលើសក់នោះ មាតាបិតា ឬអ្នកអាណាព្យាបាល នឹងត្រូវបានផ្តល់ដំណឹងជូននៅចុងថ្ងៃរៀន តាមរយៈទូរស័ព្ទ អ៊ីមែល និង/ឬ តាមរយៈកំណត់ខ្លីមួយសន្លឹក ផ្ញើជូនដល់គេហដ្ឋាន។ មាតាបិតា / អ្នកអាណាព្យាបាល នឹងត្រូវបានផ្តល់នូវព័ត៌មាន អំពីភាពមានជីវិតនៃចៃក្បាល អំពីរបៀបកំចាត់ចៃអោយអស់ពីក្បាល និងអំពីពាក្យណែនាំក្នុងការពិនិត្យរកមេចៃ និងពងចៃ។ គិលានុបដ្ឋាយកាប្រចាំសាលារៀន ឬអ្នកចាត់តាំង អាចផ្តល់ដំណឹងជូន មាតាបិតា / អ្នកអាណាព្យាពាល ចំពោះថ្នាក់រៀនដែលបានប៉ះពាល់ ដើម្បីជំរុញអោយពួកគេធ្វើការពិនិត្យលើកូនៗរបស់ពួកគេ និងដើម្បីធ្វើការព្យាបាល បើសិនសមស្រប និង/ឬ ពិនិត្យលើកូនសិស្សផ្សេងៗទៀត ដែលភាគច្រើនបានប៉ះក្បាលទល់នឹងក្បាលនៃកូនសិស្សដែលមានចៃ។ **កំណត់សំគាល់ : បើសិនជាកិច្ចសំរេចចិត្តត្រូវបានធ្វើក្នុងការផ្តល់ដំណឹងជូនជ្រាប អំពីការអាចប៉ះក្បាលគ្នានោះ ព័ត៌មានអំពីមេចៃ គោលនយោបាយ និងរបៀបឆែករកពងចៃ នឹងត្រូវបានដាក់ផ្ញើជូន។**

មាតាបិតា / អ្នកអាណាព្យាបាល នឹងត្រូវបានជំរុញអោយធ្វើការព្យាបាលកំចាត់ចៃអោយបានឆាប់រហ័ស ក្រោយពីការបានទទួលសេចក្តីជូនដំណឹង។ បើសិនជាមាតាបិតា / អ្នកអាណាព្យាបាលពុំមានលទ្ធភាពធ្វើការព្យាបាលបានទេនោះ កូនសិស្សនឹងត្រូវបានបញ្ជូនទៅកាន់ផ្នែកបំរើសេវាសុខភាព។

កូនសិស្សដែលបានប៉ះឆ្លង នឹងពុំត្រូវបានជំរុញអោយប៉ះក្បាលទល់នឹងក្បាលជាមួយនឹងកូនសិស្សផ្សេងៗទៀតឡើយ។ គិលានុបដ្ឋាយិកាប្រចាំសាលារៀន ឬអ្នកចាត់តាំង ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក អំពីរបៀបដោះស្រាយបញ្ហាពងចៃ និង/ឬ មេចៃនៅក្នុងថ្នាក់រៀន។

ព័ត៌មានអំពីគោលនយោបាយសំរាប់ចៃក្បាល និងអង្គហេតុអំពីចៃ នឹងត្រូវបានផ្ញើជូនដល់គេហដ្ឋាននៃមាតាបិតា ឬអ្នកអាណាព្យាបាលទាំងអស់ នៅដើមឆ្នាំសិក្សា។ **កំណត់សំគាល់ : ព័ត៌មានត្រូវមានដាក់ជូននូវគោលនយោបាយរបស់សង្កាត់សំរាប់ចៃក្បាល និងអង្គហេតុនានាអំពីចៃ។**

បុគ្គលិកត្រូវរក្សាទុកនូវសិទ្ធិឯកជនរបស់កូនសិស្ស ដែលត្រូវបានគេរកឃើញថាមានចៃលើក្បាល។